# ព្រះរាជក្រឹត្យ

នស/រកត/០៦០៧/២៣៣

## ស្ដីពី

## ការកែសម្រួលមាត្រា ៧ និងមាត្រា ៩
## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនាឆ្នាំ ២០០២
## ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំពីសម្ដេចនាយករដ្ឋមន្ត្រី ដែលបានឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០០៧

## ត្រាស់បង្គាប់

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

Downloaded from http://www.khmerlaws.com

**មាត្រា ១ ..**

ត្រូវបានកែសម្រួល មាត្រា ៧ និងមាត្រា ៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ដូចតទៅ ÷

**មាត្រា ៧ ថ្មី ..**

ការប្រឡងជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៨ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ហើយមានសញ្ញាប័ត្រផ្នែកណាមួយយ៉ាងទាបដូចខាងក្រោម ÷

- សញ្ញាប័ត្រគិលានុបដ្ឋាក គិលានុបដ្ឋាយិកាមធ្យម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម
- សញ្ញាប័ត្រព្យាបាលដោយចលនាមធ្យម និងសញ្ញាប័ត្រជំនាញផ្នែកបច្ចេកទេសថែទាំ និងអមវេជ្ជសាស្ត្រឯទៀត ដែលមានតម្លៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ដោយឡែក ការប្រឡងជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមសម្រាប់ជំនាញឆ្មបមធ្យម ត្រូវធ្វើឡើងដោយទូលាយក្នុងចំណោមនិស្សិតដែលមានសញ្ញាប័ត្រឆ្មបមធ្យម ហើយមានអាយុច្រើនបំផុត ៣០ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង ។

ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រឡងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីលក្ខខណ្ឌនៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤០ ឆ្នាំ ។

**មាត្រា ៩ ថ្មី ..**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលមធ្យមត្រូវចាត់ឱ្យបម្រើការងារនៅតាមអង្គភាពសុខាភិបាលខេត្ត-ក្រុង និង ថ្នាក់កណ្តាល ដោយផ្អែកលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំងជាមន្ត្រីសុខាភិបាលមធ្យម ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលមធ្យមដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនោះត្រូវតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី ៣ ។ ចំពោះមន្ត្រីសុខាភិបាលមធ្យមជំនាញឆ្មបមធ្យម ត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី ៣ ។

មន្ត្រីសុខាភិបាលមធ្យមដែលជ្រើសរើសចេញពីមន្ត្រីរាជការរបស់ក្រសួងសុខាភិបាល ពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ មន្ត្រីរាជការជ្រើសរើសចេញមកពីក្រសួង-ស្ថាប័នផ្សេងទៀត ត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ៦ ខែ ។

Downloaded from http://www.khmerlaws.com

មន្ត្រីសុខាភិបាលមធ្យមដែលបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិទី ៣ ក្នុងថ្នាក់ ដែលមានសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់ របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលមធ្យមដែលធ្វើកម្មសិក្សាមិនបានសម្រេចជោគជ័យ ត្រូវអនុញ្ញាតឱ្យបន្តធ្វើកម្មសិក្សាលើកទី ២ ទៀត ។ ក្នុងករណីមិនទទួលជោគជ័យលើកទី ២ កម្មសិក្សាការីដែលជ្រើសរើសចេញពីនិស្សិត ត្រូវលុបឈ្មោះចេញ ។ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សាសម្រាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

មាត្រា ២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ .-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៧

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាសំបន្ទាប់**

នស/រកត.០៦០៧.២៤៥

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខៈ ២៤១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃឹុន ជិនកេន**

Downloaded from http://www.khmerlaws.com